មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេបស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស

## *មូលន័យសង្ខេប*

## សេចក្តីផ្តើម

ក្នុងរយៈកាលជាងពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានឆ្លងកាត់កំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ សេដ្ឋកិច្ចរបស់ប្រទេសបានរក្សាអត្រាកំណើន ៨% ចន្លោះឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០១៨ ដោយមានកំណើនខ្ពស់រយៈពេលបួនឆ្នាំ នៅក្នុងឆ្នាំ២០១៨ ធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសដែលមានកំណើនឆាប់រហ័សជាងគេបំផុតនៅអាស៊ីបូព៌ានៅក្នុងឆ្នាំ២០១៨ និងជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចឆាប់រហ័សបំផុតនៅលើពិភពលោក។ នៅខណៈពេលដែលមានការកត់សម្គាល់ថា នៅក្នុងឆ្នាំ ២០២០ គេបានមើលឃើញការលំបាក និងភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរមួយចំនួន នៅក្នុងប្រទេស ដោយសារតែផលវិបាកផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាតសកលកូវីដ-១៩ នៅទូទាំងសកលលោកក៏ដោយ ក៏កំណើនសេដ្ឋកិច្ចជាទូទៅនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះនៅកម្ពុជាមានលក្ខណៈល្អប្រសើរផងដែរ ដូចជា ការឈានទៅរកការកាត់បន្ថយភាពក្រីក្រ ការបោះជំហានទៅមុខលើវិស័យសុខភាពមាតានិងទារក ព្រមទាំងកំណើននៃការអប់រំនៅគ្រប់កម្រិត។ ទោះបីជាយ៉ាងណាក៏មានការកត់សម្គាល់អំពីការកើនឡើងនៃទំនាស់ដីធ្លីនៅទូទាំងប្រទេសក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះផងដែរ។

បច្ចុប្បន្ន ផ្នែកសំខាន់ៗនៃដីធ្លីត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បង្កើតរោងចក្រ និងចម្ការ និងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងជាញឹកញាប់ ត្រូវបានជួលទៅឱ្យក្រុមហ៊ុនធំៗ និងអភិជនជាអ្នកនយោបាយ តាមរយៈសម្បទានដីសេដ្ឋកិច្ច ទៅលើទំហំដីប្រមាណជាងពីរលានហិកតា។ នេះបានបង្ហាញជាបញ្ហាស្របជាមួយនឹងប្រព័ន្ធចុះបញ្ជីដីធ្លីនៅមានភាពខ្វះចន្លោះរបស់ប្រទេសកម្ពុជា ទំនាក់ទំនងទៅនឹងប្រវត្តិសាស្រ្តមានលក្ខណៈជាប្រព័ន្ធដែលត្រូវបានអនុវត្ត និងបន្សល់ទុកតាំងពីអំឡុងរបបខ្មែរក្រហម ដែលជាមូលហេតុនៃដីធ្លីមួយចំនួនធំមិនទាន់ត្រូវបានចុះបញ្ជីនៅទូទាំងប្រទេស។ ដោយសារតែអសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី កង្វះខាតបណ្ណកម្មសិទ្ធិជាផ្លូវការ និងនីតិរដ្ឋទន់ខ្សោយ រលកនៃការរឹបអូសយកដីធ្លី និងការបណ្តេញចេញដោយបង្ខំបានកើតឡើងជាបន្តបន្ទាប់។ ជាលទ្ធផល នាពេលបច្ចុប្បន្ន ការរំលោភបំពានលើសិទ្ធិដីធ្លីជាលក្ខណៈប្រព័ន្ធ គឺជាបញ្ហាសិទ្ធិមនុស្សដែលកើតឡើងញឹកញាប់បំផុតនៅក្នុងប្រទេសកម្ពុជា។




ផ្នែកដ៏សំខាន់មួយនៃបញ្ហានេះ គឺមានការលំបាកដើម្បីឱ្យក្រុមហ៊ុននានាឱ្យត្រូវមាននូវគណនេយ្យភាពចំពោះផលប៉ះពាល់លើសិទ្ធិមនុស្សរបស់ពួកគេ។ ធុរកិច្ចនៅទូទាំងសកលលោកគឺ មានផលប៉ះពាល់ដោយផ្ទាល់ឬដោយប្រយោលចំពោះសិទ្ធិមនុស្សត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ នេះគឺជាភ័ស្តុតាងដ៏សំខាន់នៅក្នុងទំនាស់ដីធ្លីដោយសារតែក្រុមហ៊ុននានា តែងត្រូវបានចោទប្រកាន់ពីបទរឹបអូសយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការមិនគោរពសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។ តាមទ្រឹស្តី សហគមន៍នានានៃប្រទេសកម្ពុជាគួរតែអាចស្វែងរកដំណោះចំពោះការរំលោភបំពានលើសិទ្ធិដីធ្លីទាំងនេះតាមរយៈវិធីសាស្ត្រជាច្រើន ដែលរួមមាន តាមរយៈក្រុមហ៊ុនដោយផ្ទាល់ តាមរយៈក្រសួងដែលពាក់ព័ន្ធរបស់រដ្ឋាភិបាល និងតាមរយៈតុលាការក្នុងស្រុក ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ការស្វែងរកគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មគឺជាការពិបាក។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) បានធ្វើការលើបញ្ហាដីធ្លីនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីពេលដែលអង្គការនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២មក។ ជាផ្នែកមួយនៃគម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស ម.ស.ម.ក បានធ្វើការស្រាវជ្រាវដើម្បីវាយតម្លៃអំពីស្ថានភាពទំនាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់នៃទំនាស់ដីធ្លីទាំងនោះមកលើសិទ្ធិមនុស្ស ដោយបានសហការជាមួយអង្គការអោក់សិនអេតកម្ពុជា។ នៅក្នុងរបាយការណ៍នេះ ម.ស.ម.ក ផ្តោតលើបញ្ហាប្រឈមនៅក្នុងការស្វែងរកគណនេយ្យភាពរបស់ក្រុមហ៊ុនសាជីវកម្មនៅក្នុងទំនាស់ដីធ្លីទាំងបួន ដោយបានត្រួតពិនិត្យមើលយន្តការផ្សេងៗគ្នាជាច្រើន ដែលប្រជាពលរដ្ឋរងគ្រោះដោយសារការ

រំលោភបំពានលើសិទ្ធិដីធ្លីនៅក្នុងប្រទេសកម្ពុជាអាចស្វែងរកបាន និងវិធីសាស្ត្រដែលសហគមន៍ប្រើប្រាស់ដើម្បីទទួលបាននូវដំណោះស្រាយ។ ម.ស.ម.ក បានសម្គាល់ឃើញទំនាស់ដីធ្លីចំនួនបួនករណី ដែលបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ១៨០០ គ្រួសារ៖ ទំនាស់ដីធ្លីរវាងសហគមន៍ជនជាតិដើមភាគតិច និងក្រុមហ៊ុនចំការកៅស៊ូ សុកហ៊ិន ខេស៊ីឌី នៅក្នុងខេត្តមណ្ឌលគិរី ទំនាស់រវាងអ្នកភូមិ និងក្រុមហ៊ុនស្ករ មីតផ៉រ ភូល នៅក្នុងខេត្តឧត្តរមានជ័យ ទំនាស់រវាងអ្នកភូមិ និងក្រុមហ៊ុន អឹម.ឌី.អេស នៅតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា នៅក្នុងខេត្តពោធិ៍សាត់ និងចុងក្រោយ ទំនាស់រវាងភូមិ និងក្រុមហ៊ុនឧស្សាហកម្មស្ករកោះកុង ខូ អែល ធី ឌី និងក្រុមហ៊ុនចម្ការកោះកុង ខូ អែល ធី ឌី។

## របកគំហើញ

ម.ស.ម.ក បានពិនិត្យតាមដានយ៉ាងលម្អិតលើទំនាស់ដីធ្លីទាំងនេះ និងបានចុះត្រួតពិនិត្យដល់ទីតាំងចំនួន ១៣ លើក នៅចន្លោះឆ្នាំ២០១៧ និង២០២០ បានធ្វើសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន អ្នកតំណាងក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ និងសហគមន៍ ដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីជម្លោះទាំងនោះ។ ម.ស.ម.ក ក៏បានធ្វើការស្រាវជ្រាវ ទៅលើច្បាប់ និងបទដ្ឋានពាក់ព័ន្ធនានា និងការស្រាវជ្រាវអំពីក្រុមហ៊ុនសាជីវកម្មផងដែរ។

នៅលើឯកសារក្របខណ្ឌច្បាប់នៃប្រទេសកម្ពុជា បានអនុញ្ញាតឱ្យមានកិច្ចការពាររឹងមាំគួរសមចំពោះសិទ្ធិដីធ្លី។ ក្របខណ្ឌច្បាប់នេះចែងអំពីការពិគ្រោះយោបល់ដ៏មានអត្ថន័យ កិច្ចការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ និងបានធានាចំពោះសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី។ ស្រដៀងគ្នានេះដែររាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានទទួលស្គាល់អំពីភាពធ្ងន់ធ្ងរនៃបញ្ហាទំនាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា និងបានប្រកាសជាសាធារណៈនូវវិធានការជាច្រើនដែលនឹងត្រូវអនុវត្តដើម្បីដោះស្រាយទំនាស់ទាំងនោះ។ ប៉ុន្តែការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា ជាក់ស្តែង ស្ថានភាពនៅតែមានភាពធ្ងន់ធ្ងរ។ មិនត្រឹមតែទំនាស់ភាគច្រើនដែលយើងបានសិក្សាតាមដាននៅតែបន្តកើតឡើងនោះទេ នៅក្នុងករណីជាច្រើននៅតែមានការស្នើសុំដំណើរការដោះស្រាយទំនាស់ និងដំណោះស្រាយផ្សេងទៀត។ នៅក្នុងករណីទាំងបួន សហគមន៍ដែលជាប់ពាក់ព័ន្ធនឹងទំនាស់ដីធ្លី បានប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើននៅក្នុងការស្វែងរកគណនេយ្យភាពសាជីវកម្ម និងទទួលបានដំណោះស្រាយ។ ជាលទ្ធផលនៃការស្រាវជ្រាវនេះ ម.ស.ម.ក បានរកឃើញមានបញ្ហាសំខាន់ៗចំនួនប្រាំបួន នៅក្នុងការស្វែងរកដំណោះស្រាយសម្រាប់ទំនាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា ប្រសិនបើបញ្ហាទាំងនេះត្រូវបានដោះស្រាយ គឺនឹងអាចមានភាពប្រសើរឡើងនូវប្រសិទ្ធផល និងភាពយុត្តិធម៌ក្នុងការទទួលបាន

ដំណោះស្រាយសម្រាប់ជនដែលទទួលរងផលប៉ះពាល់ដោយសារការរំលោភបំពានលើសិទ្ធិនានា និងកាត់បន្ថយភាពស្មុគស្មាញ និងលក្ខណៈដែលបង្កភាពអន្តរាយនៃទំនាស់ដីធ្លី៖

- **របកគំហើញទី១** – កង្វះខាតការប្តេជ្ញាចិត្ត ការចូលរួម និងតម្លាភាពពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរមូលដ្ឋាននៅក្នុងការដោះស្រាយទំនាស់ដីធ្លី
- **របកគំហើញទី២**–កង្វះខាតចំណេះដឹងរបស់ភាគីដែលពាក់ព័ន្ធ ស្តីពីសិទ្ធិដីធ្លី ទំនាស់ និងដំណើរការដោះស្រាយ
- **របកគំហើញទី៣**–កង្វះខាតយន្តការដោះស្រាយនៅក្នុងប្រទេស
- **របកគំហើញទី៤**–កង្វះខាតឆន្ទៈ និងការប្តេជ្ញាចិត្ត ពីក្រុមហ៊ុនដែលជាប់ពាក់ព័ន្ធនឹងទំនាស់ដីធ្លី
- **របកគំហើញទី៥**–ដំណោះស្រាយដែលមាននោះ មិនបានបំពេញតាមបទដ្ឋានសិទ្ធិមនុស្ស
- **របកគំហើញទី៦** – កង្វះខាតការពិចារណាអំពីផលប៉ះពាល់សិទ្ធិមនុស្សរបស់សហគមន៍ក្នុងការបែងចែកដីធ្លី
- **របកគំហើញទី៧**–សហគមន៍ត្រូវបានរារាំងក្នុងការធ្វើការតស៊ូមតិដើម្បីសិទ្ធិរបស់ខ្លួនដោយសេរី
- **របកគំហើញទី៨**–ផលប៉ះពាល់មិនស្មើគ្នាចំពោះស្ត្រី និង
- **របកគំហើញទី៩**–ការប្រើកម្លាំង និងការតាំងទីលំនៅថ្មីមិនមានការស្ម័គ្រចិត្ត។

## អនុសាសន៍

កំណត់ត្រាសង្ខេបនេះបញ្ចប់ដោយលើកឡើងនូវ**អនុសាសន៍ចំនួន ២៦** សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុននានាដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា និងអង្គការសង្គមស៊ីវិល ដែលគូសបញ្ជាក់អំពីវិធានការសាមញ្ញៗដើម្បីការពារសិទ្ធិមនុស្សបានល្អប្រសើរឡើង និងសម្រេចបាននូវគណនេយ្យភាពសាជីវកម្មសម្រាប់ទំនាស់ដីធ្លីនៅក្នុងប្រទេសកម្ពុជា រួមមាន៖

- ធ្វើឱ្យប្រសើរនូវដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកាត់បន្ថយហានិភ័យនៃទំនាស់ដីធ្លីជាអប្បបរមា ដែលរួមបញ្ចូលទាំង **ការបង្កើនតម្លាភាពនៅក្នុងដំណើរការ ការប្រឹក្សា**

**យោបល់ដ៏មានអត្ថន័យ**ជាមួយសហគមន៍ និងជានាចំពោះការអនុវត្តដោយអនុលោមភាពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹង**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

- **បញ្ឈប់ជាបន្ទាន់នូវការបណ្តេញចេញពីដីធ្លីដោយបង្ខំ និងដោយហិង្សា**
- ជានាបាននូវ**តម្លាភាព**ក្នុងនាមរដ្ឋាភិបាល និងធុរកិច្ច នៅក្នុងការដោះស្រាយទំនាស់ដីធ្លី
- ជានាចំពោះ**ការដោះស្រាយទំនាស់ដីធ្លី**ឱ្យបានទាន់ពេលវេលា និងដោយយុត្តិធម៌ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពក្នុងការប្រើប្រាស់យន្តការបណ្តឹងសារទុក្ខ
- **ផ្តល់ដំណោះស្រាយដោយយុត្តិធម៌** ដែលអនុលោមតាមបទដ្ឋានអន្តរជាតិដល់ជនរងគ្រោះដោយសារការបំពានលើដីធ្លី
- **បញ្ឈប់ការពិនិត្យតាមដាន ការយាយី និងការដាក់ទោសអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនដីធ្លី**
- ធ្វើឱ្យប្រសើរឡើងនូវ**កិច្ចការពារស្ត្រី** និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។

## អំពីគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស

កំណត់ត្រាសង្ខេបនេះ ជាផ្នែកមួយនៃគម្រោង "ពង្រឹងសមត្ថភាពដល់អង្គការសង្គមស៊ីវិល ក្នុងការធ្វើការតស៊ូមតិដើម្បីបង្កើនការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនសាជីវកម្មនៅក្នុងវិស័យដីធ្លី" ដែលត្រូវបាន អនុវត្តរួមគ្នាដោយ ម.ស.ម.ក និងអង្គការអាក់សិនអេតកម្ពុជា។ គម្រោងនេះមានបំណងធ្វើឱ្យការប្រតិបត្តិរបស់ក្រុមហ៊ុនសាជីវកម្មមានភាពល្អប្រសើរឡើងតាមរយៈ ការតស៊ូមតិដើម្បីឱ្យអាជ្ញាធរធ្វើនិយ័តកម្មការប្រតិបត្តិរបស់ក្រុមហ៊ុនសាជីវកម្ម តាមរយៈការគាំទ្រសិទ្ធិរបស់សហគមន៍ និងការបង្កើនការយល់ដឹង និងតាមរយៈការបន្តបរិយាកាសអំណោយផលដែលប្រកបដោយសុវត្ថិភាពដល់សង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីបង្កើតឱកាសសម្រាប់កិច្ចសន្ទនា និងកិច្ចសហការរវាងរដ្ឋាភិបាល តួអង្គសាជីវកម្ម សហគមន៍ក្នុងមូលដ្ឋាន និងអង្គការសង្គមស៊ីវិល និងធ្វើឱ្យលេចចេញជារូបរាងនូវការអនុវត្តស្តង់ដារធុរកិច្ច និងសិទ្ធិមនុស្សនៅក្នុងវិស័យដីធ្លី។ ព័ត៌មានបន្ថែមអំពីគម្រោងនេះអាចស្វែងរកបាននៅទីនេះ។

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងគោរពសិទ្ធិមនុស្សនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិមនុស្សជាមូលដ្ឋាន ត្រូវបានផ្តល់អំណាចដើម្បីចូលរួមនៅក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកអត្ថប្រយោជន៍ពីការអភិវឌ្ឍរបស់ប្រទេសកម្ពុជាស្មើៗគ្នា។

ម.ស.ម.ក លើកកម្ពស់នីតិរដ្ឋជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងសង្គមសេរីពហុបក្សដែលភាពចម្រុះត្រូវបានគេស្វែងរក និងអបអរសាទរជាជាងការមិនអើពើ ឬការដាក់ទោស។

ម.ស.ម.ក គឺជាសមាជិកនៃអង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិ (“IFEX”) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (“OMCT”) ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អេស.អូ.អេស និងសម្ព័ន្ធ Civicus និងជាសមាជិក OECD-Watch ផងដែរ។ គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ម.ស.ម.ក ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ “សិទ្ធិ និងសេរីភាព” និងទទួលបានពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គមនៅសកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសប៊ែន ប្រទេសអូស្ត្រាលី។

## ចម្ងល់ និងមតិចូលរួម

របាយការណ៍នេះ រួមទាំងការបោះពុម្ពផ្សាយផ្សេងទៀតទាំងអស់របស់ ម.ស.ម.ក មានដាក់នៅលើគេហទំព័រ www.cchrcambodia.org និង www.sithi.org ។

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីកំណត់ត្រាសង្ខេបនេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់មតិចូលរួមណាមួយ សូមផ្ញើអ៊ីមែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org។

ឬ សូមទូរស័ព្ទមកកាន់យើងខ្ញុំ តាមរយៈលេខ +៨៥៥ (០) ២៣ ៧២ ៦៩ ០១ ឬទាក់ទងមកកាន់យើងខ្ញុំនៅផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។